# បទពិសោធគំរូទាក់ទងការកែប្រែជនជាប់ឃុំជាស្ត្រី ដែលមានកូនតូចៗនៅជាមួយ

## ការកែប្រែច្បាប់ និងទម្លាប់ទាក់ទងនឹងជនជាប់ឃុំជាស្ត្រី ដែលមានកូនតូចៗនៅជាមួយ ត្រូវបានធ្វើឡើងតាមរយៈការតស៊ូមតិ និងការបង្កើតភាពជាដៃគូ



ជនជាប់ឃុំជាស្ត្រីកម្ពុជាក្នុងពន្ធនាគារ

កត្តាដែលនាំឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារចំពោះស្ត្រីនៅប្រទេសកម្ពុជា មានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងស្ថានភាពនៅទូទាំងពិភពលោក៖ កត្តាចម្បង គឺស្ត្រីទាំងនោះមានប្រភពមកពីចង្កោមមនុស្សក្រីក្រ និងមិនត្រូវបានគេយកចិត្តទុកដាក់។ ស្ត្រីទាំងនោះភាគច្រើនធ្លាប់ទទួលរងការរំលោភបំពានផ្លូវកាយ ឬផ្លូវចិត្ត ឬឥទ្ធិពលនៃសារធាតុញៀន ហើយជាទូទៅពួកគេបានប្រព្រឹត្តបទលហុ ឬបទល្មើសស្រាលមិនមានលក្ខណៈហិង្សា។ ផ្ទុយទៅវិញ ប្រព័ន្ធយុត្តិធម៌កម្រនឹងពិចារណាដាក់ទោសផ្សេងជំនួសឲ្យការការឃុំខ្លួនស្ត្រីទាំងនោះណាស់ ហើយស្ត្រីដែលមានកូនតូចនៅជាមួយ ជារឿយៗកម្រនឹងត្រូវគេដាក់ឲ្យនៅក្រៅពន្ធនាគារ ឬឲ្យនៅក្រៅឃុំណាស់។ ដូច្នេះយើងឃើញថាវាមានការខិតខំប្រឹងប្រែងតិចតួចក្នុងការគិតគូរដល់ជីវភាពក្រុមគ្រួសាររបស់ពួកគេ សូម្បីតែនៅក្នុងករណីដែលស្ត្រីនោះគឺមេគ្រួសារដ៏សំខាន់ ឬជាអ្នកផ្គត់ផ្គង់គ្រួសារតែម្នាក់គត់ក៏ដោយ។ ការឃុំខ្លួនគាត់ក្នុងពន្ធនាគារ អាច មានផលអាក្រក់ខ្លាំងទៅលើក្រុមគ្រួសារគាត់ ជាពិសេស ទៅលើកូនតូចៗ។

ដូច្នេះ ស្ថានភាពជនជាប់ឃុំជាស្ត្រីបានក្លាយជាកង្វល់ដ៏ធំមួយ សម្រាប់កម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគាររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) ដែលកម្មវិធីនេះបានប្រកាសបើកជាផ្លូវការនៅឆ្នាំ២០០៨។ ក្នុងនោះកង្វល់ជាពិសេស គឺការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនស្ត្រីដែលជាប់ឃុំក្នុងពន្ធនាគារ (រវាងឆ្នាំ២០០៨ និងឆ្នាំ២០១២ ចំនួនស្ត្រីនៅក្នុងពន្ធនាគារបានកើនឡើងដល់ ៩៨% ធៀបទៅនឹងការកើនឡើងនៃបុរសនៅក្នុងពន្ធនាគារគឺ៣៨%)។ ការណ៍ដែលស្រីមានចំនួនជាង ៨% នៃចំនួនជនជាប់ឃុំនៅក្នុងពន្ធនាគារ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី៣០ ពីលេខរៀងទីមួយ ក្នុងចំណោមប្រទេសនៅទូទាំងពិភពលោក សម្រាប់សមាមាត្ររបស់ខ្លួននៃចំនួនស្ត្រីជាប់ឃុំក្នុងពន្ធនាគារ។ ជាការឆ្លើយតប ការិយាល័យOHCHR បានជួយក្នុងការធ្វើសេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារក្នុងឆ្នាំ២០១១ ដើម្បីធានាឲ្យមានសេចក្តីយោងជាក់លាក់ចំពោះតម្រូវការពិសេសរបស់ស្ត្រី និងបានលើកកម្ពស់ការយល់ដឹងអំពីវិធាន អ.ស.ប សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ជាស្ត្រី និងវិធានការមិនឃុំខ្លួន សម្រាប់ស្ត្រីជាជនល្មើស (វិធានក្រុងបាំងកក)។ ការិយាល័យOHCHR បានខិតខំប្រឹងប្រែងតស៊ូមតិជុំវិញប្រព្រឹត្តកម្ម លក្ខខណ្ឌ និងការដោះលែង នៅពេលណាដែលសមស្រប នូវស្ត្រី និងកូនតូចៗរបស់ពួកគាត់ពីពន្ធនាគារ ហើយវាត្រូវបានពង្រីកបន្ថែមទៀតនៅក្នុងឆ្នាំ២០១១ នៅពេលដែលការិយាល័យOHCHR បានធ្វើការក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ គឺអង្គការលីកាដូ និងអង្គការ អ៊ីល នូដូ - ដើម្បីគាំទ្រដល់ការងាររបស់ពួកគេ ជាមួយនឹងហិរញ្ញប្បទានចំនួន ១៦.៣០០ ដុល្លារអាមេរិក ដើម្បីផ្តល់សេវាកម្មដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូនតូចៗនៅជាមួយនៅក្នុងពន្ធនាគារ និងលើកបញ្ហាគោលនយោបាយមកធ្វើការតស៊ូមតិ។ តាមរយៈភាពជាដៃគូនេះ ការិយាល័យOHCHR បានបង្ហាញឲ្យដឹងថា ការតាមដានទូទៅនៃចំនួនជនជាប់ឃុំ ដោយ អាជ្ញាធរពន្ធនាគារ មិនបានរួមបញ្ចូលការការកត់ត្រាកុមារតូចៗដែលនៅជាមួយស្ត្រីជាម្តាយនៅក្នុងពន្ធនាគារទេ។ ជាលទ្ធផល ដោយរួមជាមួយដៃគូរបស់ខ្លួន ការិយាល័យOHCHR និងបានចងក្រង និង

វិភាគស្ថិតិ និងព័ត៌មានស្តីពីស្ត្រី និងស្ត្រីដែលមានកូនតូចនៅជាមួយនៅក្នុងពន្ធនាគារ បានធ្វើការជាមួយអាជ្ញាធរពន្ធនាគារនិងម្តាយរបស់កុមារ ដើម្បីកំណត់ពីកុមារដែលមានអាយុច្រើនពេក សម្រាប់ការស្នាក់នៅក្នុងពន្ធនាគារ និងបានសម្រួលការគាំទ្រ ដើម្បីជួយក្រុមគ្រួសារនៅខាងក្រៅពន្ធនាគារ ក្នុងការថែរក្សាកុមារនៅពេល "ដោះលែង" ពួកគេ ។ ស្ថិតិ និងករណីសិក្សា ត្រូវបានប្រើប្រាស់សម្រាប់ការតស៊ូមតិ និងការបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងដើម្បីបញ្ជាក់ពីចំនួនខ្ពស់ខ្លាំង នៃជនជាប់ឃុំមានផ្ទៃពោះ និងស្ត្រីដែលមានកូនតូចៗនៅជាមួយនៅពន្ធនាគារខេត្តមួយចំនួន។ ការិយាល័យOHCHRក៏បានគាំទ្រផងដែរលើការដោះស្រាយជាយុទ្ធសាស្ត្រលើសំណុំរឿងមួយចំនួនហើយដែលជាលទ្ធផលគឺស្ត្រីត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។

ចាប់តាំងពីការប្រកាសជាផ្លូវការនូវគំនិតផ្តួចផ្តើមនេះមក កំណើននៃចំនួនជនជាប់ឃុំជាស្ត្រីមានសភាពថេរ។ ដោយគួបផ្សំជាមួយនឹងការអំពាវនាវឲ្យមានកំណែទម្រង់ការដោះលែងជនជាប់ឃុំឲ្យបានទាន់ពេលវេលា កិច្ចខិតខំប្រឹងប្រែងរបស់ការិយាល័យOHCHR និងអង្គការដៃគូរបស់ខ្លួន បានរួមចំណែកដល់ការដោះលែងស្ត្រី និងកុមារចំនួន ១៦ នាក់ នៅក្នុងឆ្នាំ២០១៥ - ការលើកលែងទោស ដោយសំអាងលើឧត្តមប្រយោជន៍របស់កុមារ និងការយល់ដឹងប្រសើរជាងមុន អំពីបញ្ហាយេនឌ័រនៅក្នុងពន្ធនាគារ។

"នេះគឺជាកិច្ចសហការមួយល្អបំផុត ហើយនៅពេលណាដែលយើងមានបញ្ហាជាមួយនឹងការចូលពន្ធនាគារ យើងតែងតែទូរស័ព្ទទៅការិយាល័យOHCHR។ ការិយាល័យOHCHR បានជួយផងដែរ ឲ្យយើងផ្សព្វផ្សាយជាសាធារណៈនូវស្ថិតិស្តីពីស្ត្រីនៅក្នុងពន្ធនាគារ ហើយជាលទ្ធផល យើងអាចធ្វើការតស៊ូមតិរបស់យើងកាន់តែមានប្រសិទ្ធភាពថែមទៀត។ ទោះបីជា រយៈពេលអនុវត្តជំនួយហិរញ្ញប្បទានបានផុតហើយក្តី ក៏កិច្ចសហប្រតិបត្តិការល្អនៅតែបន្តមាន។"

លោកស្រី អាន សារវិនប្រូជ (Anne Scharrenbroich)

ទីប្រឹក្សាគម្រោងពន្ធនាគារនៃអង្គការលីកាដូ

មិថុនា ២០១៥